សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ

## ក្រោមប្រធានបទ ធម្មយាត្រាមានប្រយោជន៍ និងធម្មយាត្រាខុសឆ្គង ។

www.hoksavann.org

ថ្ងៃទី១២ វិច្ឆិកា ២០១១



អ្នកប្រាជ្ញស្រាវជ្រាវប្រវត្តិព្រះពុទ្ធសាសនាចង់ដឹងការពិតថា ព្រះពុទ្ធត្រាស់ដឹងពិតប្រាកដឬទេ ? ភស្តុតាងជាច្រើនដែលគេយកមកសំអាងថា ព្រះពុទ្ធពិតជាត្រាស់ដឹងពិតប្រាកដមែន គឺកន្លែងព្រះប្រសូតត្រាស់ដឹងសំដែងធម្មចក្របរិនិព្វន ដើមពោធិព្រឹក្ស ព្រះសារីរិកធាតុនៃព្រះអង្គនៅប្រទេសនេប៉ាល់ និងប្រទេសឥណ្ឌាសព្វថ្ងៃនេះ ។សំអាងមួយគឺ គម្ពីរព្រះត្រៃបិដក ដែលមានជំរៅជ្រាលជ្រៅបំផុត ដែលក្រៅពីអ្នកត្រាស់ដឹងសំដែង មនុស្សធម្មតាមិនអាចសំដែងបានឡើយ ។ សំអាងដ៏រឹងមាំមួយទៀត គឺមគ្គប្រកបដោយអង្គ៨ ដែលរួមមកបានដល់សីលសមាធិនិងបញ្ញា ដែលជាផ្លូវប្រតិបត្តិឆ្ពោះទៅរកការត្រាស់ដឹងជាព្រះពុទ្ធ ។

គ្រប់ជនជាតិដែលគោរពព្រះពុទ្ធសាសនា ដែលនៅក្នុងចំណោមនោះមានពុទ្ធសាសនិកជនខ្មែរ បានធ្វើដំណើរធម្មយាត្រាទៅកាន់ប្រទេសឥណ្ឌា ដើម្បីទៅថ្វាយបង្គំបូជនីយដ្ឋាននានានៃព្រះពុទ្ធ ដូចជាកន្លែងព្រះអង្គត្រាស់ដឹងនៅពោធិគយាជាដើម និងដើម្បីឲ្យឃើញភស្តុតាងថា ព្រះពុទ្ធពិតជាបានត្រាស់ដឹងពិតប្រាកដមែន ។ នៅប្រទេសកម្ពុជា ពុទ្ធសាសនិកជនខ្មែរកាន់ព្រះពុទ្ធសាសនា៩៥% មានពុទ្ធសាសនិកជនខ្មែរខ្លះ ដែលមានលទ្ធភាពបានទៅប្រទេសឥណ្ឌា ដើម្បីពិនិត្យមើលបូជនីយដ្ឋានរបស់ព្រះពុទ្ធទាំងនោះឲ្យដឹងការពិត ។ ការសិក្សាស្រាវជ្រាវឲ្យដឹងការពិតនេះ ជាសកម្មភាពមានប្រយោជន៍សំរាប់ខ្លួនជឿការត្រាស់ដឹងរបស់ព្រះពុទ្ធបានច្បាស់លាស់ផង ហើយផ្សាយឲ្យពុទ្ធសាសនិកជនខ្មែរ ដែលមិនបានទៅបានដឹងផង ។ ប្រយោជន៍សំខាន់នៃការធ្វើដំណើរធម្មយាត្រាទៅពិនិត្យមើលបូជនីយដ្ឋាននានានៃព្រះពុទ្ធ មានន័យដូចពោលមកហើយ ។ មានអ្នកដឹកនាំធម្មយាត្រាខ្លះនិយាយឃោសនាជ្រុលថា បើបានទៅថ្វាយបង្គំបូជនីយដ្ឋានទាំងនោះ នឹងរួចចាកអបាយភូមិ ។ បើអ្នកនោះបានសម្លាប់គេ បានលួចប្លន់ទ្រព្យសម្បត្តិជាដើម ពុំអាចរួចចាកពីអបាយភូមិបានឡើយ ទោះបីបានទៅថ្វាយបង្គំទីនោះក៏ដោយ ។ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនៅក្នុងចិត្ត បើគេមិនបានទៅ ប៉ុន្តែគេលើកដៃហើយតាំងចិត្តថ្វាយបង្គំនៅទីនោះ ក៏បានបុណ្យដែរ ។ ផ្ទុយទៅវិញ ជនជាតិឥណ្ឌាដែលរស់នៅក្បែរនោះ មិនជឿមិនគោរពបូជនីយដ្ឋានទាំងនោះ ការរស់នៅក្បែរនោះក៏គ្មានបានផលអ្វីឡើយ គឺគ្មានបានបុណ្យអ្វីឡើយ បើប្រមាថថែមទៀត នឹងទទួលផលបាបទៅវិញ ។

តាមរយៈវីដេអូ នៅប្រទេសឥណ្ឌាមានធម្មយាត្រាខ្មែរមួយក្រុមពីប្រទេសកម្ពុជា បានទូលព្រះសារីរិកធាតុម្ខាក់ម្តងៗ ចាត់ចែងដោយព្រះសង្ឃមួយអង្គជាតិបរទេស ។ ព្រះសង្ឃនោះមានអាកប្បកិរិយាពុំសង្រួម វាសព្រះហត្ថចុះឡើង ច្រានប៉ះស្ត្រីឲ្យថយចេញ ឲ្យស្ត្រីបន្តមើលព្រះសារីរិកធាតុ ។ ចម្លែកមួយទៀត អ្នកដឹកនាំធម្មយាត្រាខ្មែរ បានឃោសនាឲ្យរៃបច្ច័យ អ្នកខ្លះមិនត្រឹមតែចូលបច្ច័យរាប់រយដុល្លារទេ ថែមទាំងចូលពេជ្រ មាស ខ្សែក ខ្សែដៃថែមទៀត ។ សទ្ធាជ្រុលនេះ ដោយជឿតាមពាក្យអ្នកដឹកនាំឃោសនាថា បានអនិសង្សបែបនេះបែបនោះ ។ ព្រះសង្ឃជាតិបរទេសនោះបានបច្ច័យរាប់ម៉ឺន និងមាសពេជ្រជាច្រើនទៀត ដោយគ្រាន់តែយកកោដិមួយមកបង្ហាញ ជាមួយអ្វីដែលគេថាជាធាតុព្រះពុទ្ធ ។ ខ្មែរមានសទ្ធាណាស់ទោះបីរបស់ក្លែងក្លាយក៏ដោយ ឲ្យតែគេថាជាធាតុព្រះពុទ្ធ ក៏ជឿគ្មានសង្ស័យ ។ ការបូជាព្រះពុទ្ធដោយប្រាក់ពេជ្រមាស តើព្រះពុទ្ធសព្វព្រះទ័យក្នុងការបូជានេះឬទេ ។ តើព្រះសង្ឃបរទេសនោះសប្បាយចិត្តយ៉ាងណា គ្រាន់តែទទួលបាយទឹកមួយពេលបានប្រាក់ដុល្លាររាប់ម៉ឺន និងមាសពេជ្រថែមទៀត ដោយមធ្យោបាយឲ្យទូលកោដិនិងអ្វីមួយដែលគេថាជាព្រះសារីរិកធាតុ ។

តាមយើងដឹង ការដឹកនាំជាក្រុមដោយទៅទស្សនាជាច្រើនកន្លែង គេពុំធ្វើដូចអ្នកដឹកនាំខ្មែរទេ គឺគេរៃគ្នាស្ងាត់ៗឲ្យហើយបូជាកន្លែងណាប៉ុន្មានៗ កន្លែងណាដែលគួរបូជា គឺគេគិតឲ្យហើយ គេមិនឃោសនាដោយចំហ រហូតនិយាយរបៀបបង្ខំដោយសួរថា អ្នកណាចូលប៉ុន្មានទៀតដូច្នេះឡើយ ។ បានសេចក្តីថា គេបូជាជាក្រុម ។ វត្តបរទេសនៅឥណ្ឌា ជាពិសេសវត្តនៅប្រទេសស្រីលង្កា ស្ទើរតែយកព្រះសារីរិកធាតុនៃព្រះពុទ្ធធ្វើជំនួញ (Business) នៅពេលក្រុមធម្មយាត្រាខ្មែរសុំបើកមើលសំដែងអាកប្បកិរិយាតឹងតែង នៅពេលប្រគេនប្រាក់រាប់រយរាប់ពាន់ដុល្លារ ទើបសំដែងកាយវិការរាក់ទាក់បើកឲ្យមើល ។ ពេលខ្លះកាត់ថ្លៃត្រង់ៗតែម្តង ត្រូវឲ្យ Donation ប៉ុណ្ណោះ ទើបបើកឲ្យមើល ។ បើសំដែងអាកប្បកិរិយាមិនសមរម្យទៅតាមព្រះធម៌បែបនេះក្រុមធម្មយាត្រាខ្មែរសូមកុំចង់មើលមិនសំខាន់រឿងមើលទេសំខាន់នៅលើផ្លូវចិត្តនឹកដល់គុណព្រះពុទ្ធពេលណាបានបុណ្យពេលនោះ ឯធាតុនោះជាដីទឹកភ្លើងខ្យល់ ពុំដឹងជាធាតុពិតឬពុំពិតផង គ្រាន់តែថាជាធាតុព្រះដើម្បីដុល្លារប៉ុណ្ណោះ ព្រោះគ្មានអ្នកជំនាញការណាធ្វើការពិសោធន៍មើលទេ ។ សំខាន់បំផុត ខ្មែរមានសទ្ធាត្រូវប្រើបញ្ញា ជាពិសេសអ្នកដឹកនាំធម្មយាត្រា កុំបញ្ចេញវោហាសាស្ត្រលើសពីព្រះធម៌ រហូតសមាជិកនៃធម្មយាត្រាអស់បច្ច័យជាសោហ៊ុយត្រឡប់មកផ្ទះវិញ ។

បញ្ហាមួយទៀត មេដឹកនាំធម្មយាត្រាម្នាក់បានធ្វើបុណ្យចំរើនព្រះជន្ម នៅវត្តស្រីលង្កាជិតពោធិគយានៃប្រទេសឥណ្ឌា ។ ការចំរើនព្រះជន្មនៅប្រទេសឥណ្ឌា ដែលធ្វើឲ្យសិស្សនៅប្រទេសកម្ពុជាខំធ្វើដំណើរមកចូលរួមរាប់រយនាក់ ត្រូវចំណាយអស់បច្ច័យជាច្រើន ។ មួយទៀតមិនចំរើនព្រះជន្មនៅវត្តខ្មែរទេ បែរជាទៅចំរើនព្រះជន្មនៅវត្តបរទេសទៅវិញ ។ នេះសុទ្ធសឹងជាសកម្មភាពពុំសមរម្យ ។ បើចំរើនព្រះជន្មនៅប្រទេសកម្ពុជា ខ្មែរដែលត្រូវជាសិស្សមិនចំណាយថវិកាច្រើនក្នុងការធ្វើដំ-

ណើរមកចូលរួម ។

កន្លងមក មានអ្នកអធិប្បាយធម៌តាមវិទ្យុនៅភ្នំពេញប្រទេសកម្ពុជាពីរបីនាក់ បានផ្តល់ពត៌មានរបៀបឃោសនាថា ខ្លួននឹងទៅធ្វើទស្សនកិច្ចនៅប្រទេសចិនកុម្មុយនិស្ត ដើម្បីថ្វាយបង្គំព្រះចង្កូមកែវ ។ អំពីបញ្ហាទាឋធាតុ (ព្រះចង្កូមកែវ) របស់ព្រះពុទ្ធថាព្រះចង្កូមកែវមួយចិនកុម្មុយនិស្តបានអះអាងថានៅប្រទេសរបស់ខ្លួន ។ ប៉ុន្តែបើយោងតាមគម្ពីរព្រះត្រៃបិដកភាគ១៦ ទំព័រ ៣៤៩ និងទំព័រ៣៥០ ព្រះចង្កូមកែវទាំង៤របស់ព្រះពុទ្ធ ពុំឃើញចែងថានៅប្រទេសចិនទេ ។ បន្ទាប់ពីផ្តល់ពត៌មានតាមវិទ្យុ មានពុទ្ធសាសនិកជនខ្មែរជាច្រើន ផ្ញើបច្ច័យរហូតមាសពេជ្រទៅបូជាព្រះចង្កូមកែវ ។ អ្នកដឹកនាំធម្មយាត្រាទៅប្រទេសចិន បានទទួលប្រាក់និងមាសពេជ្រពីអ្នកបរិច្ចាគទៅឲ្យចិនកុម្មុយនិស្តក្រោមរូបភាពបូជាព្រះចង្កូម ថែមទាំងរាប់ឈ្មោះតាមវិទ្យុ ហើយនិយាយប្រាប់ពីអានិសង្សឲ្យខ្មែររាប់លាននាក់ស្តាប់ផង ។ នេះជាការនិយាយឃោសនា ធ្វើឲ្យខ្មែរលង់គំនិតជាអំពើមិនត្រូវធ្វើសោះឡើយ ។ នេះជាការខុសឆ្គងរបស់អ្នកដឹកនាំពុទ្ធសាសនានិយាយឃោសនា ហើយទទួលយកមាសពេជ្រចេញពីប្រទេសរបស់ខ្លួន នៅពេលដែលប្រទេសកម្ពុជាកំពុងមានភាពក្រែក្រ ។ ដោយមានការរិះគន់ ទើបយកមាសពេជ្រទាំងនោះត្រឡប់មកវិញខ្លះ យកមកធ្វើសុវណ្ណកោដិ ។៚

*            *

*